53/10

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨៨៣ អក
ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥
សាលក្រមសម្រេចលើបណ្តឹងទាស់
លេខ ២៨ (ឋ)
ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០

**គោរពនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី៣០ ខែមករា ឆ្នាំ ២០២០ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីតា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងទាស់របស់ឈ្មោះ គុយ ធីតា ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨៨៣ អ.ក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៥ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២១ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន (គេចខ្លួន)

២.ឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងផ្សារដែក មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤ នាក់ ជានីតិជន (ឃុំខ្លួន)

៣.ឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ១៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និង [redacted] ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន (គេចខ្លួន)

ជាប់ចោទពីបទ៖ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។



CamScanner

## **អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី០៣.១០.២០០៥ ម៉ោងប្រហែល ៩ យប់ ឈ្មោះ [redacted] មុត និងបងឈ្មោះ [redacted] មួន បាននាំគ្នាដើរទៅមើលគេចាក់បាស់រាំនៅភូមិត្បូងដំរី ក្នុងឃុំកំពង់ចម្លង ពេលទៅដល់កន្លែងរាំ ឈ្មោះ [redacted] មុត បានចូលទៅអង្គុយផឹកស្រាជាមួយឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស នៅខាងត្បូងសាលាឆទានតួព្រះធាតុ ជិតរង់រាំ ដល់ម៉ោងប្រហែល ១១ បងរបស់ឈ្មោះ [redacted] មុត ឈ្មោះ [redacted] មួន ត្រឡប់ទៅផ្ទះមុន នៅម៉ោងប្រហែល ១១ និង ៣០ នាទី ឈ្មោះ [redacted] ឆៃហារ បានដើរទៅកន្លែងគ្រែដែលឈ្មោះ [redacted] មុត បានចាក់ស្រាមួយកែវហុចឱ្យឈ្មោះ [redacted] ឆៃហារ ផឹក លុះដល់ម៉ោង ១២ ឈ្មោះ [redacted] រតនា,ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស បាននាំគ្នាដើរ ចេញទៅទិញខាងត្បូងបាត់ទទៅ ពេលនោះឈ្មោះ [redacted] ឆៃហារ ឃើញឈ្មោះ [redacted] មុត ស្រវឹងខ្លាំងក៏បានសុំខ្លួនជូនទៅផ្ទះ តែឈ្មោះ [redacted] មុត តបថា មិនអីទេសុទ្ធតែពួកម៉ាកខ្ញុំទេ បន្ទាប់មកពួកគេទាំង៥ នាក់ នាំគ្នាដើរចេញពីកន្លែងផឹកបាត់អស់ទៅ ចាប់ពីពេលនោះមកឈ្មោះ [redacted] មុត បាត់ខ្លួនរហូតមិនឃើញចូលផ្ទះ លុះដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៥ ម៉ោងប្រហែល ៩ព្រឹក ស្រាប់តែឃើញសាកសពឈ្មោះ [redacted] មុត អណ្តែតក្នុងទឹកព្រែកសំបួរដែលហូរចេញពីទន្លេតូច ស្ថិតក្នុងភូមិសំបួរ ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ហើយនៅលើសាកសពមានស្នាមជាំត្រង់កញ្ចឹងក ១ កន្លែង ជាំលើចង្កេះ ១ កន្លែង និងស្នាមមុតលើខ្នង ៣ កន្លែង ជាស្នាមមុតដោយអាវុធមុខស្រួច។

ក្រោយពីស្រង់សាកសពយកមកដល់ផ្ទះ ជនសង្ស័យឈ្មោះ [redacted] រតនា ,ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស បាននាំគ្នារត់គេចខ្លួនបាត់ពីផ្ទះរហូត។

បានឃើញ សាលក្រមលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកណ្តាល ដែលបានសម្រេចសេចក្តី៖

១-ផ្តន្ទាទោស៖

ក-ជនជាប់ចោទឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២១ ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

ខ-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២១ ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

គ-ជនជាប់ចោទឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ១៩ ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] រស់) នៅលីវ ជានីតិជន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

ពីបទ៖ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។



CamScanner

153
8

២-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ប្រុស ,ឈ្មោះ [redacted] ភេទនា និងឈ្មោះ [redacted] ធីតា រួមគ្នាសងជម្ងឺចិត្តប្រាក់ចំនួន១៥ លានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន។ ដើមបណ្តឹងទាមទារលើសពីនេះបដិសេធចោល។

៣-ចេញដីកាចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទនា ,ឈ្មោះ [redacted] ធីតា និងជនជាប់ចោទឈ្មោះ [redacted] ប្រុស គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារឱ្យជនជាប់ចោទ តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ភេទនា ,ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញ កំណត់ហេតុឱ្យដំណឹងពីសាលក្រមកំបាំងមុខ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ដែលឈ្មោះ [redacted] ធីតា បានប្តឹងទាស់នឹងសាលក្រមលេខៈ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ នេះ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ធីតា បានឆ្លើយថា មុនពេលកើតហេតុ ខ្ញុំទៅមើលគេរាំធុងបាស់ ទៅម្នាក់ឯង ពេលទៅដល់កន្លែងរាំបានស្គាល់អ្នកភូមិជាច្រើន ខ្ញុំមិនបានផឹកស្រាជាមួយឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ភេទនា ទេ ។ ពេលខ្ញុំចេញពីផ្ទះម៉ោងប្រហែល៤ ល្ងាច ទៅដល់កន្លែងធុងបាស់ប្រហែលម៉ោង៦ ល្ងាច ហើយខ្ញុំត្រឡប់មកផ្ទះវិញម៉ោងប្រហែល៩ យប់។ ពេលរាំធុងបាស់មានមនុស្សច្រើនណាស់ ខ្ញុំចាំមិនអស់ទេ មនុស្សស្លាប់នោះខ្ញុំមិនបានស្គាល់ទេ គ្មានទំនាក់ទំនងជាមួយគ្នាទេ ហើយក៏មិនធ្លាប់មានទំនាស់ជាមួយគ្នាដែរ។ នៅថ្ងៃកើតហេតុខ្ញុំរាំធុងបាស់ផ្សេង ជនរងគ្រោះរាំធុងបាស់ផ្សេងនៅឆ្ងាយពីគ្នា ខ្ញុំមិនបានវាយទៅលើជនរងគ្រោះទេ ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្ញុំហ៊ានស្បថឱ្យស្លាប់ចោលកូនទាំង៤ នាក់ ចំពោះឈ្មោះ [redacted] ភេទនា និងឈ្មោះ [redacted] ប្រុស ខ្ញុំមិនដឹងថាគាត់ពាក់ចញ្ចៀនឬក៏អត់ទេ។ ខ្ញុំមិនបានសងសំណងជនរងគ្រោះទេ តែម្តាយខ្ញុំគាត់ចូលបុណ្យនោះខ្ញុំក៏មិនដឹងដែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ន បានឆ្លើយថា ជនរងគ្រោះត្រូវជាប្អូនខ្ញុំ ខ្ញុំដឹងថាប្អូនខ្ញុំបានផឹកស្រាជាមួយឈ្មោះ [redacted] ប្រុស ,ឈ្មោះ [redacted] ភេទនា តែឈ្មោះ [redacted] ធីតា ទៅផ្ទះមុន ពេលដឹងដំណឹងថាប្អូនស្លាប់ ខ្ញុំក៏ដើររក តែមិនដឹងថាអ្នកណាជាអ្នកសម្លាប់ទេ អង្គហេតុនោះខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ។ ខ្ញុំបានទទួលលុយចំនួន ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិក ពីម្តាយ [redacted] ធីតា បានចូលបុណ្យ។

-សាក្សីឈ្មោះ [redacted] រដ្ឋា បានឆ្លើយថា ខ្ញុំត្រូវជាបងបង្កើតរបស់ឈ្មោះ [redacted] ធីតា ខ្ញុំបានឃើញប្អូនប្រុសរបស់ខ្ញុំត្រឡប់មកពីរាំធុងបាស់វិញនៅម៉ោងប្រហែលម៉ោង៩ ម៉ោង១០ យប់ ដេកក្នុងផ្ទះ។

-សាក្សីឈ្មោះ [redacted] ស៊ីថា បានឆ្លើយថា ខ្ញុំត្រូវជាប្រពន្ធជនជាប់ចោទឈ្មោះ [redacted] ធីតា ខ្ញុំរៀបការនៅក្នុងឆ្នាំ២០១០,២០១១ ខ្ញុំស្គាល់គ្នាជាមួយប្តីខ្ញុំបាន១ឆ្នាំ ទើបរៀបការ។ ខ្ញុំដឹងថាប្តីខ្ញុំមិនបានប្រព្រឹត្តទេ ពេររស់នៅជាមួយខ្ញុំ ខ្ញុំរស់នៅក្នុងភូមិជាមួយគ្នាឃុំហើយតាំងពីឆ្នាំ២០០៤,២០០៥ ក្នុងចន្លោះឆ្នាំនោះ ខ្ញុំឮគេថាមានមនុស្សស្លាប់ តែមិនដឹងថាអ្នកណាជាអ្នកសម្លាប់ទេ។

-សាក្សីឈ្មោះ [redacted] ចំរើន បានឆ្លើយថា ខ្ញុំត្រូវជាម្តាយរបស់ឈ្មោះ [redacted] ធីតា ខ្ញុំមិនដឹងថាជនរងគ្រោះស្លាប់ដោយសារអ្នកណាសម្លាប់ទេ ពេលស្លាប់ខ្ញុំចូលទាំងលុយ ទាំងអង្ករ អង្ករប្រហែល២ ល្ហីហើយលុយប្រហែលជិត២ លានរៀល ដោយសារអ្នកស្លាប់ត្រូវជាក្មួយ និងការខ្វះខាតរបស់ជនរង



CamScanner

៦.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ ៣៥ឆ្នាំ ពីបទៈ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៧.យល់ឃើញថា សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំនុចទី១ និងចំនុចទី២ នៃសម្រេចមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការតម្កល់ទុកជាបានការដដែល។

## ហេតុដូច្នេះសម្រេច

១.ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ៣៥ឆ្នាំ ទុកជាត្រឹមត្រូវតាមផ្លូវច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ទុកជាបានការដដែល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីតា។

- ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| [redacted] | [redacted] | [redacted] | [redacted] |



CamScanner